**ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១០)**

| | |
|---|---|
| **ឈ្មោះសេវា** | **ការផ្តល់សេវាពិនិត្យសំណើសុំ គោលការណ៍អាជ្ញាប័ណ្ណនាំចេញ-នាំចូលផល-អនុផលព្រៃឈើ** |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>-អគារលេខ ៤០មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញភ្នំពេញ<br>-ទូរស័ព្ទ ០១២-៨០២៦៩៩ ទូរសារ (៨៥៥) ២៣-២១១ ៦៣៦<br>-គេហទំព័រ www.forestry.gov.kh |
| **គោលបំណងនៃសេវា** | ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម នាំចេញ-នាំចូលផល-អនុផលព្រៃឈើ |
| **មូលដ្ឋានគតិយុត្តិ** | -ច្បាប់ស្តីពីព្រៃឈើ មាត្រា ២៥-២៦-៥២-៧២ និង ៧៣<br>-អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦<br>-ប្រកាសអន្តរក្រសួង លេខ ១០០ ប្រក.កសក ចុះថ្ងៃទី ២៧ ខែ កុម្ភះ ឆ្នាំ ១៩៩៥<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវការអនុញ្ញាតលើសំណើសុំគោលការណ៍អាជ្ញាប័ណ្ណមានការប្រែប្រួលទៅតាមករណីនីមួយៗអាស្រ័យទៅតាមលទ្ធផលនៃការវាយតម្លៃលើភាពស្រប ឬមិនស្របច្បាប់នៃផល អនុផលព្រៃឈើនិងលក្ខណៈគ្រប់គ្រាន់នៃសំណុំឯកសារដែលបានស្នើសុំ ។ក្នុងរយៈពេល៣ថ្ងៃនៃថ្ងៃការងារនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិនឹងជូនដំណឹងទៅរូបវន្តបុគ្គលឬនីតិបុគ្គលអំពីភាពស្រប ឬមិនស្រប និងលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃសំណុំឯកសារដែលបានស្នើសុំ<br>-តំលៃ (នឹងកំណត់នៅពេលក្រោយ) ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | - ពាក្យស្នើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចេញ-នាំចូល ច្បាប់ដើម (០២ ច្បាប់)<br>-ឯកសារបញ្ជាក់អំពីប្រភេទផល-អនុផលព្រៃឈើ(Packing Lists)និងវិក័យប័ត្រ (Invoices) (ច្បាប់ដើម)<br>- ឯកសារបញ្ជាក់ពីប្រភពវត្ថុធាតុដើមផល-អនុផលព្រៃឈើស្របច្បាប់<br>- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម<br>- លក្ខន្តិកៈរបស់ក្រុមហ៊ុន (ច្បាប់ដើម) ។ |
| **យោបល់** | ដំណើរការនៃការស្នើសុំគោលការណ៍អាជ្ញាប័ណ្ណនាំចេញនាំចូល ផល-អនុផល ព្រៃឈើចែកចេញជា៣ដំណាក់កាល(១) ការដាក់ពាក្យស្នើសុំ(២) ការពិនិត្យផ្តល់មតិរបស់នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ (៣) លិខិតរបស់រដ្ឋបាលព្រៃឈើជូនក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បី ពិនិត្យសំរេច ។ |

៙៙៙✵៚៚៚

## ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១១)

| | |
|---|---|
| **ឈ្មោះសេវា** | **ការផ្តល់សេវាពិនិត្យលើសំណើសុំ អាជ្ញាប័ណ្ណនាំចេញ-នាំចូលផល-អនុផល ព្រៃឈើ** |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>-អគារលេខ៤០មហាវិថីព្រះនរោត្តមសង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>-ទូរស័ព្ទ ០១២-៨០២៦៩៩ ទូរសារ (៨៥៥) ២៣-២១១ ៦៣៦<br>-គេហទំព័រ www.forestry.gov.kh |
| **គោលបំណងនៃសេវា** | ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម នាំចេញ-នាំចូលផល-អនុផលព្រៃឈើ |
| **មូលដ្ឋានគតិយុត្តិ** | -ច្បាប់ស្តីពីព្រៃឈើ មាត្រា ២៥-២៦-៥២-៧២ និង ៧៣<br>-អនុក្រឹត្យលេខ ១៣១ អនក្រ.បកស្តីពីយថាប្រភេទផលអនុផលព្រៃឈើអនុញ្ញាតឱ្យ នាំចេញ នាំចូល មាត្រា ៦-៧-៨។<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨<br>-ប្រកាសអន្តរក្រសួង លេខ ១០០ ប្រក.កសក ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រសួង ពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលិខិតបទដ្ឋានពាក់ព័ន្ធ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវទិដ្ឋាការអាជ្ញាប័ណ្ណមានការប្រែប្រួលទៅតាមករណី នីមួយៗ អាស្រ័យទៅតាមលទ្ធផលនៃការវាយតម្លៃលើភាពស្រប ឬមិនស្រប ច្បាប់នៃផល អនុផលព្រៃឈើ និងលក្ខណៈគ្រប់គ្រាន់នៃសំណុំឯកសារ ដែលបានស្នើសុំ ។ក្នុងរយៈពេល ៣ថ្ងៃនៃថ្ងៃការងារ នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ នឹងជូន ដំណឹងទៅរូបវន្តបុគ្គល ឬនីតិបុគ្គលអំពីភាពស្រប ឬមិនស្រប និងលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃសំណុំឯកសារ ដែលបានស្នើសុំ ។<br>-ថ្លៃសេវានាំចេញ នាំចូល ១ % នៃ FOB ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | -ពាក្យស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូល ច្បាប់ដើម (០២ ច្បាប់)<br>-លិខិតផ្តល់គោលការណ៍អនុញ្ញាតអោយនាំចេញ នាំចូលរបស់គណៈរដ្ឋមន្ត្រីឬដែល ចេញដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-បញ្ជីរាយលំអិតនូវប្រភេទផល អនុផលព្រៃឈើ (Packing Lists) និងវិក័យប័ត្រ (Invoices) ច្បាប់ដើម<br>-ឯកសារបញ្ជាក់ពីប្រភពផល-អនុផលព្រៃឈើស្របច្បាប់<br>-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម<br>-លក្ខន្តិកៈរបស់ក្រុមហ៊ុនច្បាប់ដើម |

| | |
|---|---|
| | -ប័ណ្ណបង់ប្រាក់និងបង្កាន់ដៃបង់ប្រាក់ថ្លៃសួយសារផលអនុផលព្រៃឈើនិងថ្លៃសេវាកម្ម ១ % នៃតម្លៃផលិតផលនៅច្រកនាំចេញ-នាំចូល (FOB)<br>-សន្លឹកអាជ្ញាប័ណ្ណដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។ |
| **យោបល់** | ដំណើរការនៃការស្នើសុំ និងបំពេញបែបបទសុំទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញនាំចូលផល-អនុផល ព្រៃឈើ ចែកចេញជា ៣ ដំណាក់កាល (១)ការដាក់ពាក្យស្នើសុំ (២)ការពិនិត្យផ្តល់មតិ របស់នាយកដ្ឋាន ឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ (៣)ការផ្តល់ទិដ្ឋាការ អាជ្ញាប័ណ្ណនាំចេញ-នាំចូល ដោយប្រធានរដ្ឋបាលព្រៃឈើ ។ |

ឰឰឰ*ឱឱឱ

## ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១២)

| | |
|---|---|
| **ឈ្មោះសេវា** | **ការផ្តល់សេវាពិនិត្យសំណើសុំបង្កើត មូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ និងសិប្បកម្មកែច្នៃផល_អនុផលព្រៃឈើ** |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>-អគារលេខ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>-ទូរស័ព្ទ ០១២-៨០២៦៩៩ ទូរសារ (៨៥៥) ២៣-២១១ ៦៣៦<br>- គេហទំព័រ www.forestry.gov.kh |
| **គោលបំណងនៃសេវា** | ដើម្បីសម្រួលដល់ការធ្វើអាជីវកម្ម អារ កែច្នៃ ផល-អនុផលព្រៃឈើ |
| **មូលដ្ឋានគតិយុត្តិ** | - ច្បាប់ស្តីពីព្រៃឈើ មាត្រា ២៥-២៦-៧១ និង ១០៧<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | ពេលវេលាចាំបាច់ដើម្បីទទួលបាននូវច្បាប់អនុញ្ញាតមានការប្រែប្រួលទៅតាមករណីនីមួយៗ អាស្រ័យទៅតាមលទ្ធផលនៃការវាយតម្លៃលើភាពស្រប ឬ មិនស្របច្បាប់នៃប្រភពផ្គត់ផ្គង់ ផល អនុផលព្រៃឈើ ទីតាំង និងលក្ខណៈគ្រប់គ្រាន់នៃសំណុំឯកសារដែលបានស្នើសុំ ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | ១- ប្រវត្តិរូបសង្ខេប<br>២- ព័ត៌មានពិស្តារបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន<br>៣- ឯកសារបញ្ជាក់ប្រភពផ្គត់ផ្គង់វត្ថុធាតុដើម(ផល អនុផលព្រៃឈើ) ឬកិច្ចសន្យា<br>៤- ប្លង់កម្មសិទ្ធិនៃទីតាំងស្នើសុំ ឬកិច្ចសន្យាជួលដី ឬទីតាំង |

| | |
|---|---|
| | ៥- កិច្ចសន្យារបស់ម្ចាស់រោងឧស្សាហកម្ម រោងចក្រ ឬសិប្បកម្មចំពោះសមត្ថកិច្ចរដ្ឋបាល ព្រៃឈើមូលដ្ឋាន<br>៦- លិខិតសុវិធាន និងអសុវិធាន( សេចក្តីយល់ព្រមរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញទីតាំងរោងឧស្សាហកម្ម រោងចក្រឬសិប្បកម្មដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី<br>៧- បញ្ជីរាយនាមគ្រឿងចក្រ-សំភារៈឧបករណ៍កែច្នៃផល អនុផលព្រៃឈើ<br>៨- គូសប្លង់ទីតាំង និង ប្លង់បច្ចេកទេស រោងឧស្សាហកម្ម រោងចក្រ ឬ សិប្បកម្មដោយ មានបញ្ជាក់ និងយល់ព្រមពីសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់<br>៩- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម និងប័ណ្ណប៉ាតង់ ប្រចាំដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ<br>១០- លក្ខន្តិកៈរបស់ក្រុមហ៊ុនច្បាប់ដើម<br>១១- កំណត់ហេតុ និងរបាយការណ៍វាយតម្លៃលក្ខណៈបច្ចេកទេស និងទីតាំងស្នើសុំ ។ |
| **យោបល់** | ដំណើរការនៃការស្នើសុំនិងបំពេញបែបបទសុំច្បាប់អនុញ្ញាតបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ ឬសិប្បកម្មកែច្នៃ ផល អនុផលព្រៃឈើចែកចេញជា ៣ ដំណាក់កាល( ១) ការដាក់ពាក្យស្នើសុំ( ២) ការពិនិត្យផ្តល់មតិរបស់នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និង សហប្រតិបត្តិការអន្តរជាតិ ( ៣) ការសំរេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ |

៙៙៙❋៚៚៚

## ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៣)

| | |
|---|---|
| **ឈ្មោះសេវា** | **ការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូន ផលអនុផលព្រៃឈើ នាំចេញ-នាំចូល និងដឹកជញ្ជូនឆ្លងកាត់** |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>- អគារលេខ៤០ មហាវិថីព្រះនរោត្តមសង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ ០១២-៨០២៦៩៩ ទូរសារ ( ៨៥៥) ២៣-២១១ ៦៣៦<br>- គេហទំព័រ www.forestry.gov.kh |
| **គោលបំណងនៃសេវា** | ដើម្បីគ្រប់គ្រងការធ្វើចរាចរនាំចេញ-នាំចូល ផល-អនុផលព្រៃឈើ |
| **មូលដ្ឋានគតិយុត្តិ** | - ច្បាប់ស្តីពីព្រៃឈើ មាត្រា ២៥-២៦ និង ២៧<br>- អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ |

| | |
|---|---|
| | - ប្រកាសលេខ ៣៦៧ ប្រក.កសក ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤<br>- ប្រកាសលេខ ០៩០ ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដាសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវលិខិតអនុញ្ញាតនេះមានការប្រែប្រួលទៅតាមករណី នីមួយៗអាស្រ័យទៅតាមលទ្ធផលនៃការពិនិត្យលើភាពស្រប ឬមិនស្របច្បាប់នៃប្រភព ផល អនុផលព្រៃឈើ និងលក្ខណៈគ្រប់គ្រាន់នៃសំណុំ ឯកសារដែលបាន ស្នើសុំ។ ក្នុងរយៈ ពេល ៣ថ្ងៃនៃថ្ងៃការងារនាយកដ្ឋានឧស្សាហកម្មព្រៃឈើនិងសហប្រតិបត្តិការអន្តរ ជាតិនឹងជូនដំណឹងទៅរូបវន្តបុគ្គលឬនីតិបុគ្គលអំពីភាពស្របឬមិនស្របនិងលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃសំណុំឯកសារ ដែលបានស្នើសុំ។<br>-តំលៃ (នឹងកំណត់នៅពេលក្រោយ)។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | -គោលការណ៍នាំចេញនាំចូលផលអនុផលព្រៃឈើដែលចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី<br>-លិខិតអនុញ្ញាតអោយនាំចេញរបស់ប្រទេសដើម<br>-គោលការណ៍នាំចេញ-នាំចូល ឬដឹកជញ្ជូនឆ្លងកាត់ ផល-អនុផលព្រៃឈើដែលចេញដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-អាជ្ញាប័ណ្ណនាំចេញ-នាំចូល ផល-អនុផលព្រៃឈើ ដែលចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ និងក្រសួងពាណិជ្ជកម្ម<br>-លិខិតបើកផ្លូវដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូល ឬឆ្លងកាត់។ |
| **យោបល់** | ដំណើរការនៃការស្នើសុំ និងបំពេញបែបបទសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ នាំចេញ- នាំចូលជាតម្រូវការចាំបាច់របស់អង្គភាពដើម្បីគ្រប់គ្រងការដឹកជញ្ជូនផល-អនុផល ព្រៃឈើ ឱ្យបាន ត្រឹមត្រូវតាមប្រភេទបរិមាណនិងចំទិសដៅ ការពារបាននូវចរាចរផលអនុផលព្រៃឈើអនាធិបតេយ្យ។ |

ឈឈឈ៙ឈឈឈ

## ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៤)

| | |
|---|---|
| **ឈ្មោះសេវា** | **ការផ្តល់សេវាកម្មដើម្បីទទួលបាននូវវិញ្ញាបនប័ត្រឈើផលិតផលព្រៃឈើសំរាប់ទីផ្សារនាំចេញ និងលើឯកត្តាគ្រប់គ្រងព្រៃឈើដោយនិរន្តភាព** |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>- អគារលេខ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>-ទូរស័ព្ទ ០១២-៨០២៦៩៩ ទូរសារ (៨៥៥) ២៣-២១១ ៦៣៦ |

| | |
|---|---|
| | - គេហទំព័រ www.forestry.gov.kh |
| **គោលបំណងនៃសេវា** | ដើម្បីបង្កើនផលិតផលសំរាប់ទីផ្សារនាំចេញ និងការគ្រប់គ្រងព្រៃឈើដោយចីរភាព |
| **មូលដ្ឋានគតិយុត្តិ** | -ច្បាប់ស្តីពីព្រៃឈើ មាត្រា ៧<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវវិញ្ញាបនប័ត្រខាងលើមានការប្រែប្រួលទៅតាមករណី នីមួយៗអាស្រ័យទៅតាមលទ្ធផលនៃការពិនិត្យវាយតម្លៃលើផលិតផល និងការគ្រប់គ្រង ព្រៃឈើ និងលក្ខណៈគ្រប់គ្រាន់នៃសំណុំ ឯកសារដែលបានស្នើសុំ ។ ក្នុងរយៈពេល ៣ថ្ងៃ នៃថ្ងៃការងារនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ នឹងជូនដំណឹងទៅរូបវ័ន្តបុគ្គល ឬនីតិបុគ្គលអំពីភាពស្រប ឬមិនស្រប និងលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ នៃសំណុំឯកសារ ដែលបានស្នើសុំ ។<br>-តំលៃ (នឹងកំណត់នៅពេលក្រោយ) ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | -លិខិតស្នើសុំការផ្តល់សេវាបញ្ជាក់វិញ្ញាបនប័ត្រលើផលិតផលព្រៃឈើ ឬលើឯកត្តាគ្រប់គ្រងព្រៃឈើ<br>-ឯកសារទ្រទ្រង់ភាពស្របច្បាប់នៃផលិតផលព្រៃឈើនាំចេញ និងការធ្វើអាជីវកម្មព្រៃឈើនៃឯកត្តាគ្រប់គ្រងនីមួយៗ<br>-របាយការណ៏ពាក់ព័ន្ធការធ្វើអាជីវកម្មកែច្នៃផលិតផល និងអំពីឯកត្តាគ្រប់គ្រងនានា ។ |
| **យោបល់** | ដំណើរការនៃការផ្តល់សេវាដើម្បីទទួលបានវិញ្ញាបនប័ត្រលើផលិតផលព្រៃឈើនាំចេញ និងលើឯកត្តាគ្រប់គ្រងព្រៃឈើជាតម្រូវការចាំបាច់របស់អង្គភាពដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តភាព និងដើម្បីបង្កើនផលិតផលព្រៃឈើនាំចេញ ។ |

៚៚៚*៙៙៙

## ព័ត៌មានអំពីសេវាកម្មផ្តល់ដោយ រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៥)

| **ឈ្មោះសេវា** | **ការផ្តល់សេវាកម្មសិក្សាវាយតម្លៃកំណត់បរិមាណស្តុកកាបូនព្រៃឈើ** |
|---|---|
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | -រដ្ឋបាលព្រៃឈើ<br>**-នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**<br>- អគារលេខ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>-ទូរស័ព្ទ ០១២-៨០២ ៦៩៩ ទូរសារ (៨៥៥) ២៣-២១១ ៦៣៦<br>- គេហទំព័រ www.forestry.gov.kh |

| | |
|---|---|
| **គោលបំណងនៃសេវា** | ដើម្បីបង្កើនចំណូលជាធនធានសំរាប់ដំណើរការអភិវឌ្ឍ និងគ្រប់គ្រងព្រៃឈើដោយចីរភាព |
| **មូលដ្ឋានគតិយុត្តិ** | -ច្បាប់ស្តីពីព្រៃឈើ មាត្រា ៧<br>-អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ |
| **អតិថិជនមានសិទ្ធិទទួលសេវា** | រូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ឬបរទេស |
| **ស្តង់ដារសេវា** | -ពេលវេលាចាំបាច់ដើម្បីទទួលបាននូវសេវាកម្មខាងលើនេះមានការប្រែប្រួលទៅតាមករណី នីមួយៗអាស្រ័យទៅតាមការងារ និងលក្ខណៈគ្រប់គ្រាន់នៃសំណុំ ឯកសារដែលបានស្នើសុំ ។ ក្នុងរយៈពេល ៣ថ្ងៃនៃថ្ងៃការងារនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការ អន្តរជាតិ នឹងជូនដំណឹងទៅរូបវន្តបុគ្គល ឬនីតិបុគ្គលអំពីភាពស្រប ឬមិនស្រប និងលក្ខណៈ គ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃសំណុំឯកសារ ដែលបានស្នើសុំ ។<br>-តំលៃ (នឹងកំណត់នៅពេលក្រោយ) ។ |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | ១- លិខិតស្នើសុំការផ្តល់សេវាសិក្សាវាយតម្លៃកំណត់បរិមាណស្តុកកាបូនព្រៃឈើ<br>២- ឯកសារទ្រទ្រង់ភាពស្របច្បាប់នៃឯកត្តាគ្រប់គ្រងព្រៃឈើ និងប្រវត្តិនៃតំបន់ព្រៃដែល ស្នើសុំការវាយតម្លៃកំណត់បរិមាណស្តុកកាបូន<br>៣-របាយការណ៍ពាក់ព័ន្ធតំបន់ព្រៃដែលស្នើសុំការវាយតម្លៃកំណត់បរិមាណស្តុកកាបូន |
| **យោបល់** | ដំណើរការនៃការផ្តល់សេវាដើម្បីទទួលបាននូវលទ្ធផលបរិមាណស្តុកកាបូនព្រៃឈើជាការ ចូលរួមចំណែករបស់អង្គភាពដើម្បីបង្កើនចំណូលសម្រាប់គ្រប់គ្រងព្រៃឈើដោយនិរន្តភាព ។ |

ᢀᢀᢀ❋ᢁᢁᢁ

| | |
|---|---|
| **យោបល់** | ដំណើរការនៃការស្នើសុំ និងបំពេញបែបបទសុំច្បាប់អនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ចែកចេញជា ៣ ដំណាក់កាល (១) ការដាក់ពាក្យស្នើសុំ (២) ការពិនិត្យផ្តល់មតិរបស់ខណ្ឌរដ្ឋបាលព្រៃឈើ (៣) ការសំរេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។ |

ᢀᢀᢀ❋ᢁᢁᢁ